ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

************

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤ អនក្រ-បក

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
មកដល់ថ្ងៃទី 20 ខែ 04
ឆ្នាំ 99 ម៉ោង
ចុះបញ្ជីលេខ 2019

**អនុក្រឹត្យ**

**ស្តីពីការបន្ថែមប្រាក់បៀវត្ស ជូនមន្ត្រីរាជការ**

**ស៊ីវិល យោធា នគរបាលជាតិ**

**និវត្តជន និង មន្ត្រីបាត់បង់សមត្ថភាពពលកម្ម**

************

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/ ០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នរ/រកម/០១.៩៩/០១ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការផ្ទេរចំណូល និង ផ្ទេរឥណទាន ទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- យោងការសំរេចរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៩
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយបន្ថែមប្រាក់បៀវត្ស ចំនួន ៣០ ភាគរយ លើបៀវត្សសុទ្ធសាធ ជូនមន្ត្រីរាជការ ស៊ីវិល យោធា នគរបាលជាតិ និវត្តជន និង មន្ត្រីបាត់បង់សមត្ថភាពពលកម្ម។

**មាត្រា២:** ប្រាក់បៀវត្សដែលបន្ថែម ៣០ ភាគរយនេះ ត្រូវចាប់អនុវត្ត ពីខែ ឧសភា ឆ្នាំ ១៩៩៩ តទៅ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ